នស/រកត/០៩០៤/២៨៤

# ព្រះរាជក្រឹត្យ

## ស្តីពី

## ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេច នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ត្រូវបានបង្កើត **ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ** ឱ្យទទួលបន្ទុកសម្របសម្រួល ដឹកនាំ តាមដាន ត្រួតពិនិត្យមើលការអនុវត្ត និងលើកសំណើជូនរាជរដ្ឋាភិបាលលើរាល់កិច្ចការនៃកំណែទម្រង់រដ្ឋ ការពង្រឹង អភិបាលកិច្ចល្អ និង

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

កំណែទម្រង់នានាតាមវិស័យសំខាន់ៗរបស់បណ្ដាស្ថាប័នរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

ដើម្បីបំពេញបេសកកម្ម និងសម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា ១ ខាងលើ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវបានជួយជាកម្លាំងដោយក្រុមប្រឹក្សាកំណែទម្រង់មួយចំនួន ដែលទទួលខុសត្រូវផ្ទាល់ក្នុងការផ្ដួចផ្ដើមគំនិត និងអនុវត្តនូវកម្មវិធីកំណែទម្រង់នានា ពាក់ព័ន្ធទៅនឹងក្រសួងស្ថាប័នរបស់ខ្លួន ស្ថាប័នរដ្ឋណាមួយ ឬក្នុងផ្នែកណាមួយនៃវិស័យរដ្ឋបាល សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាកំណែទម្រង់នីមួយៗ និងស្ថាប័នរដ្ឋ ដែលបំពេញការងារកំណែទម្រង់ ឬអភិបាលកិច្ចល្អ ដែលមានក្នុងព្រះរាជក្រឹត្យនេះ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាកំណែទម្រង់នីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប និងមានអគ្គលេខាធិការដ្ឋានមួយធ្វើជាសេនាធិការទទួលបន្ទុកសម្របសម្រួល ដាក់ឱ្យដំណើរការ និងតាមដានជាអចិន្ត្រៃយ៍នូវការអនុវត្តការងារដែលស្ថិតនៅក្នុងយុត្តាធិការរបស់ប្រធាន ។

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់មកចូលរួមក្នុងការប្រជុំរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

**មាត្រា ៤.-**

ដើម្បីប្រតិបត្តិបេសកកម្មដូចមានចែងក្នុងមាត្រាខាងលើឱ្យបានសម្រេចជោគជ័យ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវបំពេញមុខងារ និងភារកិច្ចដូចតទៅៈ

១- លើកសំណើស្តីពីការបង្កើត ឬការផ្លាស់ប្តូរក្រុមប្រឹក្សា ឬអង្គភាពនានា ដែលមានចរិតលក្ខណៈគតិយុត្ត ជាស្ថាប័នរដ្ឋ បំពេញការងារកំណែទម្រង់តាមវិស័យនានា និងពង្រឹងអភិបាលកិច្ច ។

២- តំរង់ទិស សម្របសម្រួល និងត្រួតពិនិត្យសកម្មភាពការអនុវត្តន៍ការងារ និងវឌ្ឍនភាពនៃលទ្ធផលទាំងអស់របស់ក្រុមប្រឹក្សា និងអង្គភាពនីមួយៗ ។

៣- លើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការតែងតាំងលិខិត និងបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិចាំបាច់សំខាន់ៗ សំរាប់ដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់នានា និងការពង្រឹងអភិបាលកិច្ចល្អ ។

៤- ចេញសេចក្តីសម្រេច និងសេចក្តីណែនាំសំខាន់ៗ ដល់ការដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់នានា នៅក្នុងយុត្តាធិការរបស់ខ្លួន ។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ មានសមាសភាពដូចតទៅៈ

| | | |
|---|---|---|
| ១- | នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- | ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- | ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |

៤- ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

៥- ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៦- ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៧- ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨- ប្រធានក្រុមប្រឹក្សា និងប្រធានអង្គភាពទាំងអស់ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ជាសមាជិក ។

អង្គការលេខរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ ដូចមានភ្ជាប់ជាមួយ ។

## ជំពូកទី ២

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៦.–**

ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ មានអគ្គស្នងការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គស្នងការមួយរូប ។ អគ្គស្នងការដ្ឋាន ប្រើប្រាស់មន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

អគ្គស្នងការនៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ មានអគ្គស្នងការរង និងក្រុមប្រឹក្សាមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គស្នងការ និងអគ្គស្នងការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

**មាត្រា ៧.–**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល គឺជាអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។ របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

**មាត្រា ៨.–**

អគ្គស្នងការ មានភារកិច្ចរៀបចំរបៀបវារៈនៃការប្រជុំនានារបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ផ្សព្វផ្សាយសេចក្តីសម្រេច សម្របសម្រួល និងតាមដានការអនុវត្តរបស់ក្រុមប្រឹក្សា និងអង្គភាពនានា ហើយនិងធ្វើរបាយការណ៍ បូកសរុបលទ្ធផលការងារ ដែលសម្រេចបានជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៩.–**

ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច មានស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១១.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ចករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខៈ ២២៨ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ណាឌី តាន់**